# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTrade Bulletin

**Infographic**
"Cambodia-Korea Free Trade Agreement"

**Local News & Global News**

**Policy At Glance**
"Impact of the COVID-19 and Russia-Ukraine Conflict on Fertilizer Prices"
*TAT Putsodary & CHAM Nimul*

វ៉ុល០២ | លេខ០៥ | ខែវិច្ឆិកា ឆ្នាំ២០២២
VOLUME 02 | ISSUE 05 | NOVEMBER 2022

# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ

**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ (CKFTA)**
គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីទី **២** របស់កម្ពុជា

## ពេលវេលានៃកិច្ចចរចាកិច្ចព្រមព្រៀង CKFTA

កិច្ចព្រមព្រៀង CKFTA ត្រូវបានបញ្ចប់ បន្ទាប់ពីការចរចា ចំនួន៩ជុំ រយៈពេលជាង១៥ ខែ

**មីនា ២០១៩**
ក្នុងកិច្ចប្រជុំកំពូលកម្ពុជា-កូរ៉េ នៅរាជធានីភ្នំពេញ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានស្នើទៅ ឯកឧត្តម មូន ជែអ៊ីន ប្រធានាធិបតីកូរ៉េ បង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-កូរ៉េ

**២៥ វិច្ឆិកា ២០១៩**
ការសិក្សារួមគ្នាស្តីពីលទ្ធភាព នៃការបង្កើត កិច្ចព្រមព្រៀង CKFTA

**៣០-៣១ កក្កដា ២០២០**
កិច្ចព្រមព្រៀង CKFTA ការចរចាជាផ្លូវការជុំទី១

**៣១ សីហា-០៣ កញ្ញា ២០២០**
កិច្ចព្រមព្រៀង CKFTA ការចរចាជាជុំទី២

**០៦-០៨ តុលា ២០២០**
កិច្ចព្រមព្រៀង CKFTA ការចរចាជាជុំទី៣

**១៨-២០ វិច្ឆិកា ២០២០**
កិច្ចព្រមព្រៀង CKFTA ការចរចាជាជុំទី៤ (តាមប្រព័ន្ធវីដេអូ)

**០៣ កុម្ភៈ ២០២១**
កិច្ចព្រមព្រៀង CKFTA សេចក្តីថ្លែងការណ៍រួម

**២៦ តុលា ២០២១**
កិច្ចព្រមព្រៀង CKFTA បានចុះហត្ថលេខាដោយ ឯ.ឧ. ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីពាណិជ្ជកម្មកម្ពុជា និង ឯ.ឧ. YEO Han-Koo រដ្ឋមន្ត្រីពាណិជ្ជកម្មសាធារណរដ្ឋកូរ៉េ (តាមប្រព័ន្ធវីដេអូ)

**២៩ មករា ២០២២**
កិច្ចព្រមព្រៀង CKFTA ត្រូវបានឡាយព្រះហស្តលេខាដោយ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី

**២៧ កញ្ញា ២០២២**
កិច្ចព្រមព្រៀង CKFTA ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ

**០១ ធ្នូ ២០២២**
កិច្ចព្រមព្រៀង CKFTA ចូលជាធរមាន

## ពាណិជ្ជកម្មទ្វេភាគី



+៥,៤%

| | |
|---|---|
| ២០២០ | ៧៣៤ លានដុល្លារ |
| ២០២១ | ៧៧៤ លានដុល្លារ |
| ២០២២ (មករា-កញ្ញា) | ៦០០,៤៣ លានដុល្លារ |

(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា)

**២០២១**
- ១.៨១១ ប៊ីលានដុល្លារ
- ៥១ លាននាក់
- ៣៤.៩៩៨ ដុល្លារ

(ប្រភព៖ IMF, World Bank)

### ការប្រៀបធៀបកម្រិតសេរីភាវូបនីយកម្មក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា ដែលកូរ៉េមានជាមួយកម្ពុជា

| កិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-កូរ៉េ (ចុះហត្ថលេខា៖ ២០០៥) | កិច្ចព្រមព្រៀងអាសិប (ចុះហត្ថលេខា៖ ២០២០) | កិច្ចព្រមព្រៀង CKFTA (ចុះហត្ថលេខា៖ ២០២១) |
|---|---|---|
| (HSK ២០១៧) | (HSK ២០១២) | (HSK ២០១៩) |
| **៨៩,៩៨%** | **៩០,៦៣%** | **៩៥,០៣%** |
| (១១២៩៤ បន្ទាត់ពន្ធគយ) | (១១០៩៦ បន្ទាត់ពន្ធគយ) | (១១០៩៦ បន្ទាត់ពន្ធគយ) |

**កម្ពុជាទទួលបានច្រកចូលទីផ្សារសេរីបន្ថែមទៀតក្រោមកិច្ចព្រមព្រៀង CKFTA ច្រើនជាងកិច្ចព្រមព្រៀង AKFTA និង RCEP។

## អត្ថប្រយោជន៍

**៩៥,០៣%**
(១១៦៥៦ បន្ទាត់ពន្ធគយ)
ផលិតផលដែលកម្ពុជានាំចេញទៅកូរ៉េ នឹងត្រូវលុបចោលការយកពន្ធ

### ទំនិញដែលនឹងចូលទៅកាន់ទីផ្សារកូរ៉េជាមួយពន្ធគយ 0% ភ្លាមៗ ក្រោយកិច្ចព្រមព្រៀងចូលជាធរមាន៖

**ទំនិញឧស្សាហកម្ម**: កង់ កៅស៊ូ គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម នំ ស្ករអំពៅ កាបូប វ៉ាលី ខ្សែ ខ្សែអគ្គិសនី សម្ភារកីឡា វាយនភ័ណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងគ្រឿងកុំព្យូទ័រ។ល។

**ផលិតផលកសិកម្ម**: ម្រេច គ្រាប់ស្វាយចន្ទី ចេក ដំឡូងបារាំង ផ្សិត មង្ឃុត ដូងម្នាស់ ឪឡឹក រមៀត ពោត ថ្នាំជក់ គ្រាប់កាហ្វេ សាច់ និងផលិតផលវារីវប្បកម្មមួយចំនួន។ល។

**ផលិតផលកែច្នៃ**: គុយទាវ នំ និងនំស្រួយធ្វើពីអង្ករ សំបុកត្រចៀកកាំ ផលិតផលកែច្នៃពីត្រី ផលិតផលកែច្នៃពីដូង ។ល។

សូមស្កេនដើម្បីទាញយកអត្ថបទ CKFTA

រៀបចំដោយ

សូមស្កេនដើម្បីទាញយក iTrade Bulletin

# CAMBODIA-KOREA FREE TRADE AGREEMENT



## 2nd BILATERAL FREE TRADE AGREEMENT

Cambodia-Korea Free Trade Agreement (CKFTA) is the Kingdom's second bilateral free trade agreement.

## CKFTA TIMELINE

**CKFTA** was concluded after 4 rounds of negotiations, spanning over 15 months.

**2019 March**
During the Cambodia-Korea Summit in Phnom Penh, **Prime Minister HUN SEN** proposed to **President MOON JAE-IN** a Cambodia-Korea bilateral FTA

**2019 Nov 25**
CKFTA
Joint Feasibility Study announced

**2020 July 30-31**
CKFTA
1st round of official negotiations held

**2020 Aug 31 - Sep 03**
CKFTA
2nd round of negotiations held

**2020 Oct 06-08**
CKFTA
3rd round of negotiations held

**2020 Nov 18-20**
CKFTA
4th round of negotiations held (Virtually)

**2021 Feb 03**
CKFTA
Joint Declaration

**2021 Oct 26**
**CKFTA** signed by the Minister of Commerce of Cambodia, **PAN Sorasak** and the Minister of Commerce of the Republic of Korea, **YEO Han-Koo** (Virtually)

**2022 Jan 29**
CKFTA
Signed into law by Cambodia's His Majesty King NORODOM Sihamoni

**2022 Sep 27**
CKFTA
Ratified by the National Assembly of the Republic of Korea

**2022 Dec 01**
CKFTA
enters into force

## BILATERAL TRADE



**2021**
1,811 US$ billion
51 million
34,998 US$

(Source: IMF, World Bank)

+5.4%

| Year | Value |
|---|---|
| 2020 | $734 million |
| 2021 | $774 million |
| 2022 (Jan - Sep) | $600.43 million |

(Source: General Directorate of Customs and Excise of Cambodia)

### Comparison of Korea's Liberalization across FTAs with Cambodia

| ASEAN-Korea FTA (Signed: 2005) | RCEP (Signed: 2020) | CKFTA (Signed: 2021) |
|---|---|---|
| (HSK 2017) | (HSK 2012) | (HSK 2019) |
| **89.98%** | **90.63%** | **95.03%** |
| (11,294 Tariff Lines) | (11,096 Tariff Lines) | (11,656 Tariff Lines) |

** Cambodia enjoys more liberalized market access into Korea under CKFTA than AKFTA and RCEP.

## BENEFITS

**95.03%**
(11,656 Tariff Lines)
**products to be exported by Cambodia to Korea will have tariffs eliminated.**

### Goods that will get 0% duty market access into Korea:

**Industrial Goods**
bicycles, rubber, electronic components, furniture, pastries, sugarcane, handbags, suitcases, cords, electrical cables, electrical cables, sports, equipment, textiles, clothing, footwear and computer accessories, etc.

**Agricultural Products**
pepper, cashew nuts, bananas, yellow potatoes, potatoes, mushrooms, mangosteen, coconut, pineapple, watermelon, turmeric, turmeric, corn, tobacco, coffee beans, meat and some aquaculture products, etc.

**Processed Products**
noodles, pastries and crisps made from rice, bird nests, processed products from fish, gourds, processed products from coconuts, etc.

Please scan to download CKFTA Text

Organized by

Please scan to download iTrade Bulletin

## ក្នុងនាមជាប្រធានអាស៊ាន កម្ពុជាទទួលបានការវាយតម្លៃខ្ពស់ចំពោះភាពរលូននៃកិច្ចប្រជុំកំពូលនានា

ប្រភព៖ Phnom Penh Post

កិច្ចប្រជុំកំពូលអាស៊ានលើកទី៤១ និង៤២ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលមានការចូលរួមពីមេដឹកនាំកំពូលៗ ដូចជា លោក ចូ បៃដិន ប្រធានាធិបតីអាម៉េរិក, លោក លី ខឺឈាង នាយករដ្ឋមន្ត្រីចិន និងលោក អាន់តូនីញ៉ូ ហ្គូទែរ៉េស អគ្គលេខាធិការអង្គការសហប្រជាជាតិ បានទាញចំណាប់អារម្មណ៍យ៉ាងច្រើនពីបណ្តាប្រទេសលើសកលលោក។ ក្នុងរយៈពេលបួនថ្ងៃ មានកិច្ចប្រជុំជាច្រើនត្រូវបានរៀបចំឡើង ដោយរួមបញ្ចូលទាំងកិច្ចប្រជុំដែលបានកំណត់ជាផ្លូវការ រួមមានកិច្ចប្រជុំអាស៊ាន-ចិន, អាស៊ាន-កូរ៉េ, អាស៊ាន-អង្គការសហប្រជាជាតិ, អាស៊ានបូក៣, អាស៊ាន-ឥណ្ឌា, អាស៊ាន-អូស្ត្រាលី, អាស៊ាន-ជប៉ុន, អាស៊ាន-កាណាដា, និង អាស៊ាន-អាម៉េរិក និងកិច្ចពិភាក្សាក្រៅផ្លូវការផ្សេងទៀត។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងនាមជាប្រធានអាស៊ាន បានថ្លែងថាឯកសារសមិទ្ធផលជាង១០០ ច្បាប់នឹងត្រូវបានអនុម័តនាប៉ុន្មានឆ្នាំខាងមុខនេះ ដើម្បីជាផែនទីបង្ហាញផ្លូវដល់សកម្មភាព និងកិច្ចសហប្រតិបត្តិការការទូតក្នុងតំបន់អាស៊ាន។ ចុចទីនេះដើម្បីអានបន្ថែម

## ពាណិជ្ជករកម្ពុជាត្រៀមខ្លួនទទួលអត្ថប្រយោជន៍ជាច្រើនក្រោយកិច្ចព្រមព្រៀង CKFTA ចូលជាធរមាន

ប្រភព៖ ក្រសួងពាណិជ្ជកម្ម

ថ្លែងក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-សាធារណរដ្ឋកូរ៉េ (CKFTA) សម្រាប់ការនាំចេញ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានគូសបញ្ជាក់ថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី CKFTA នឹងចូលជាធរមាននៅថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០២២ បន្ទាប់ពីត្រូវបានផ្តួចផ្តើមឡើងពីខែមីនា ឆ្នាំ២០១៩ ក្នុងដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ប្រធានាធិបតី MOON Jae-In នៃសាធារណរដ្ឋកូរ៉េ មកកាន់ព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមរដ្ឋមន្ត្រី បន្តថា កិច្ចព្រមព្រៀង CKFTA នឹងបំពេញបន្ថែមទៅលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-កូរ៉េ និងកិច្ចព្រមព្រៀងអាសិប (RCEP) ដែលមានស្រាប់។ នៅក្រោមកិច្ចព្រមព្រៀង CKFTA កម្ពុជាបាន បើកទីផ្សារ ចំនួន ៨៩,០៩% នៃបន្ទាត់ពន្ធគយសរុប ខណៈដែលភាគីកូរ៉េបានបើកទីផ្សារចំនួន ៩៥,០៣% នៃបន្ទាត់ពន្ធគយសរុប ដែលក្នុងនោះកម្ពុជានឹងអាចនាំចេញទំនិញក្នុងអត្រាពន្ធគយសូន្យភ្លាមៗ ចំនួន ៩២,៣៧% នៃបន្ទាត់ពន្ធគយសរុប បន្ទាប់ពីកិច្ចព្រមព្រៀងចូលជាធរមាននៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២។ ចុចទីនេះដើម្បីអានបន្ថែម

## អាស៊ានជាកម្លាំងចលករសម្រាប់ភាពជោគជ័យនៃកិច្ចព្រមព្រៀង RCEP

ប្រភព៖ Khmer Times

លោក Lim Jock Hoi អគ្គលេខាធិការអាស៊ានបានមានប្រសាសន៍ថា អាស៊ាននឹងបន្តជាកម្លាំងចលករសម្រាប់កិច្ចព្រមព្រៀងអាសិប។ លោក Lim បានបន្តថា “តាមពិតតួនាទីរបស់អាស៊ានមិនត្រូវបានកំណត់ចំពោះតែបណ្តាប្រទេសក្នុងតំបន់នោះទេ។ តំបន់នេះ ត្រូវដើរតួនាទីជាអ្នកដឹកនាំដ៏សំខាន់ក្នុងការដោះស្រាយបញ្ហាភូមិសាស្ត្រនយោបាយដែលកំពុងកើតមាន។ មានតែអាស៊ានទេដែលអាចផ្តល់វេទិកាសម្រាប់ដោះស្រាយបញ្ហានយោបាយ និងសេដ្ឋកិច្ចដែលជាបញ្ហាក្តៅសម្រាប់ពិភពលោក”។ ចំពោះករណីថាតើឥណ្ឌានឹងចូលរួមក្នុងកិច្ចព្រមព្រៀងអាសិបដែរឬទេ ក្រោយពីធ្លាប់ជាភាគីចរចានៃកិច្ចព្រមព្រៀងកាលពីប៉ុន្មានឆ្នាំដំបូង ប៉ុន្តែបានផ្អាកទៅវិញនៅប៉ុន្មានឆ្នាំក្រោយមក លោកបានតបថា ទ្វារនៅតែបើកចំហសម្រាប់ឥណ្ឌា។ តាមប្រសាសន៍របស់លោក Satvinder Singh អគ្គលេខាធិការរងសហគមន៍សេដ្ឋកិច្ចអាស៊ាន “ស្ថានភាពសេដ្ឋកិច្ចរបស់យើងកាន់តែមានភាពល្អប្រសើរ។ ក្រុមហ៊ុនអន្តរជាតិធំៗ ឥឡូវនេះងាកមកចាប់អារម្មណ៍កិច្ចព្រមព្រៀងអាសិប”។ ចុចទីនេះដើម្បីអានបន្ថែម

## កម្ពុជា និងឥណ្ឌាពង្រឹកទំនាក់ទំនងទ្វេភាគីនៅក្រៅកិច្ចប្រជុំកំពូលអាស៊ានដែលទើបនឹងបញ្ចប់

ប្រភព៖ Khmer Times

ឥណ្ឌាបានរៀបចំពង្រឹកទំនាក់ទំនងជាមួយកម្ពុជា ខណៈដែលប្រទេសទាំងពីរបានប្រារព្ធខួបលើកទី៧០នៃទំនាក់ទំនងទ្វេភាគីនៅក្នុងឆ្នាំ២០២២នេះ។ ដើម្បីបញ្ជាក់ពីទំនាក់ទំនងរវាងភាសាសំស្ក្រឹត និងភាសាខ្មែរ ស្ថានទូតឥណ្ឌាបានរៀបចំការប្រារព្ធទិវាភាសាសំស្ក្រឹត នៅក្នុងខែសីហា ឆ្នាំ២០២២ ដោយមានការចូលរួមពីអ្នកប្រាជ្ញសំស្ក្រឹតដ៏ល្បីរបស់កម្ពុជា ក៏ដូចជាសិល្បករឥណ្ឌា និងកម្ពុជាផងដែរ។ យោងតាមរបាយការណ៍ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មសរុបរវាងកម្ពុជា និងឥណ្ឌា មានចំនួន៣១១លានដុល្លារអាម៉េរិក។ ឥណ្ឌាស្ថិតក្នុងចំណោមវិនិយោគិនបរទេសកំពូលទាំង១០ក្នុងប្រទេសកម្ពុជា និងជាដៃគូពាណិជ្ជកម្មធំទី៤ក្នុងអាស៊ាន ខណៈពាណិជ្ជកម្មទ្វេភាគីឥណ្ឌា-អាស៊ានក្នុងឆ្នាំ២០១៩-២០២០ មានតម្លៃ ៨៦,៩ ប៊ីលានដុល្លារអាម៉េរិក។ កម្ពុជាមានគម្រោងបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាមួយឥណ្ឌាផងដែរ ខណៈដែលប្រទេសនេះមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយចិន កូរ៉េខាងត្បូង និងជប៉ុនរួចទៅហើយ។ ទាក់ទងនឹងការតភ្ជាប់ជារូបវន្ត ការបញ្ចប់គម្រោងផ្លូវហាយវេត្រីភាគីឥណ្ឌា-ថៃ-មីយ៉ាន់ម៉ា ដែលភ្ជាប់ទៅនឹងកម្ពុជា ឡាវ និងវៀតណាម នឹងផ្តល់ឱកាសក្នុងការបង្កើនការតភ្ជាប់ពហុម៉ូដរវាងឥណ្ឌា និងកម្ពុជា។ ចុចទីនេះដើម្បីអានបន្ថែម

## Smooth Summit Caps Kingdom's Widely Praised Year as Chair

Source: Phnom Penh Post

The 40th and 41st ASEAN Summits and Related Summits drew wide interest from nations globally, with top leaders from around the world including US President Joe Biden, China's Premier Li Keqiang and UN Secretary-General Antonio Guterres, all in attendance. Over the course of the past four days, several dozen meetings had been held – including the officially scheduled ones and the less formal discussions that took place more discreetly on the sidelines. The official count includes the ASEAN-China, ASEAN-Korea, ASEAN-UN, ASEAN+3 (China, Japan, Korea), ASEAN-India, ASEAN-Australia, ASEAN-Japan, ASEAN-Canada and ASEAN-US gatherings. Speaking in his capacity as chair of ASEAN, Prime Minister Hun Sen said that a long list of over 100 official outcome documents would be adopted to guide the bloc's actions and diplomatic cooperation in the coming years. Click here to read more

## As CKFTA to Enter into Force in December 2022, Cambodian Traders Ready to Reap Benefits

Source: Ministry of Commerce

Addressing in his opening remarks in the Dissemination Seminar on the Implementation of the Cambodia-Korea Free Trade Agreement (CKFTA) for Export on 24 November 2022, H.E. PAN Sorasak, Minister of Commerce, reiterated the entry into force of the CKFTA from 01 December 2022 following the joint initiative of the two Leaders since March 2019 during the state visit of H.E. Moon Jae-In, former President of the Republic of Korea, to Cambodia. H.E. Minister emphasized that the CKFTA will complement the existing ASEAN-Korea FTA and the RCEP to which Cambodia is also a Party. Yet, under the CKFTA, Cambodia has offered 89.09% market access to Korea and secured 95.03% vice versa, 92.37% of which will allow Cambodia to export potential products at zero-tariff rate immediately after the Agreement has entered into force. Click here to read more

## ASEAN to Be Driving Force for RCEP's Success

Source: Khmer Times

ASEAN will continue to be the driving force for the Regional Comprehensive Economic Partnership (RCEP), said Dato Lim Jock Hoi, the Secretary General of ASEAN. "This role of ASEAN, in fact, is not limited to the region. The regional grouping has to play a crucial leadership role in resolving the current geopolitical issues. Only ASEAN can provide a platform for solving the current political and economic issues rattling the world," said Dato Lim. On the issue of India, which was a party to the negotiations in the initial years and suspended the talks later, joining the RCEP, he said the door is still open for the country. The RCEP, according to Satvinder Singh, the DSG for ASEAN Economic Community, "Our economies are doing better. All major international companies now want to engage with RCEP." Click here to read more

## Cambodia and India Expand Bilateral Relations on the Sidelines of the Just Concluded ASEAN Summits

Source: Khmer Times

India prepared to expand its relations with Cambodia as they celebrate the 70th anniversary of their bilateral relations this year. To highlight the linkages between Sanskrit and the Khmer language, the Embassy of India organized Sanskrit Day celebrations in August 2022 with the participation of eminent Sanskrit scholars of Cambodia as well as Indian and Cambodian artists. As per the 2021 report, the total trade volume between Cambodia and India amounted to US $311 million. India is among the top 10 foreign investors in Cambodia and the fourth largest trading partner in ASEAN with bilateral trade in 2019-20 worth US $86.9 billion. Cambodia is also in plans to establish a bilateral Free Trade Agreement with India It already has FTA with China, South Korea and Japan. With respect to physical connectivity, the completion of the India- Thailand- Myanmar trilateral highway that is to be connected to Cambodia, Laos, and Vietnam will give India and Cambodia an opportunity to enhance multimodal connectivity. Click here to read more

## លោកស្រី Georgieva ប្រធានមូលនិធិរូបិយវត្ថុអន្តរជាតិ៖ ការបែកបាក់ពាណិជ្ជកម្មអាចធ្វើឱ្យសេដ្ឋកិច្ចពិភពលោកខាតបង់ចំនួន១,៤ ទ្រីលានដុល្លារអាមេរិក

ប្រភព៖ Business Standard

ប្រធានមូលនិធិរូបិយវត្ថុអន្តរជាតិបាននិយាយថា ការកើនឡើងនៃរបាំងពាណិជ្ជកម្មប្រឆាំងនឹងប្រទេសចិន និងប្រទេសផ្សេងទៀតកាលពីឆ្នាំមុន អាចធ្វើឱ្យសេដ្ឋកិច្ចពិភពលោកខាតបង់ទឹកប្រាក់ចំនួន១,៤ ទ្រីលានដុល្លារបន្ថែមលើការខូចខាតធ្ងន់ធ្ងរបង្កឡើងដោយសង្គ្រាមនៅអ៊ុយក្រែន។ លោកស្រី Georgieva បានប្រាប់ទូរទស្សន៍ Bloomberg ថា "អ្វីដែលខ្ញុំសង្ឃឹមនឹងឃើញ គឺការផ្លាស់ប្តូរគោលនយោបាយនានាដែលធ្លាប់ប្រឆាំងចិន និងពិភពលោក"។ "ពិភពលោកនឹងខាតបង់ ១,៥% នៃផលិតផលក្នុងស្រុកសរុបដោយសារតែការបែកបាក់ជាសកល នាំឱ្យមានប្លុកពាណិជ្ជកម្មពីរប្រជែងគ្នា ធ្វើឱ្យខាតបង់ ១,៤ ទ្រីលានដុល្លារ"។ លោកស្រី បាននិយាយនៅក្រៅកិច្ចប្រជុំមេដឹកនាំ APEC ថា ទំហំនៃការបាត់បង់នៅតំបន់អាស៊ី អាចដុនជាបទ្វេដងឬច្រើនជាង ៣% នៃផលិតផលក្នុងស្រុកសរុប ដោយសារតំបន់នេះ មានសមាហរណកម្មខ្ពស់ក្នុងខ្សែច្រវាក់តម្លៃសកល។ ចុចទីនេះដើម្បីអានបន្ថែម

## របាយការណ៍របស់អង្គការ WTO បង្ហាញពីការរឹតត្បិតពាណិជ្ជកម្មរបស់ក្រុមប្រទេស G20 ដែលកំពុងកើនឡើងចំពេលមានបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច

ប្រភព៖ WTO

យោងរបាយការណ៍ត្រួតពិនិត្យពាណិជ្ជកម្មលើកទី២៨ របស់អង្គការ WTO ស្តីពីវិធានការពាណិជ្ជកម្មរបស់ក្រុមប្រទេស G20 ដែលបានចេញផ្សាយនៅខែវិច្ឆិកា ឆ្នាំ២០២២ នៅក្នុងបរិបទនៃសេដ្ឋកិច្ចមិនប្រាកដប្រជា ដែលញាំញីដោយជំងឺរាតត្បាតកូវីដ-១៩ សង្គ្រាមនៅអ៊ុយក្រែន និងវិបត្តិសន្តិសុខស្បៀង ពីពាក់កណ្តាលខែឧសភា មកពាក់កណ្តាលខែតុលា ឆ្នាំ២០២២ ក្រុមប្រទេស G20 បានដាក់ចេញវិធានការរឹតត្បិតការនាំចេញក្នុងកម្រិតលឿនមួយ ជាពិសេសលើស្បៀងអាហារ និងជី។ លោកស្រីអគ្គនាយិកា អង្គការ WTO បានអំពាវនាវឱ្យសមាជិកនៃក្រុមប្រទេស G20 និងសមាជិកអង្គការ WTO ទាំងអស់ ឱ្យចៀសវាងការអនុម័តវិធានការរឹតត្បិតពាណិជ្ជកម្មថ្មីៗ ដែលអាចធ្វើឱ្យសេដ្ឋកិច្ចពិភពលោកកាន់តែដុនដាប។ របាយការណ៍បង្ហាញថា និន្នាការនេះបាន និងកំពុងដើរក្នុងទិសដៅខុស "ខណៈពេលដែលវិធានការរឹតត្បិតពាណិជ្ជកម្មមួយចំនួនត្រូវបានដកចេញដោយសមាជិកក្រុមប្រទេស G20។ ការរឹតត្បិតការនាំចេញនាំមកនូវកង្វះខាតស្បៀងអាហារនិងជី ការប្រែប្រួលថ្លៃលឿន និងភាពមិនច្បាស់លាស់។ ចុចទីនេះដើម្បីអានបន្ថែម

## APEC រកឃើញជំហររួមលើពាណិជ្ជកម្មសេរីនៅប៉ាស៊ីហ្វិក និងវិបត្តិសង្គ្រាមអ៊ុយក្រែន

ប្រភព៖ Nikkei Asia

កិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិកបានបញ្ចប់ ដោយមេដឹកនាំមកពីសមាជិកទាំង ២១ បានចេញសេចក្តីថ្លែងការណ៍រួម ដែលនិយាយអំពីបញ្ហាសង្គ្រាមនៅអ៊ុយក្រែន ដែលជាវិបត្តិធ្វើឱ្យក្រុមប្រទេសនេះបានបែកបាក់សាមគ្គីគ្នាពេញមួយឆ្នាំ។ ការចេញសេចក្តីថ្លែងការណ៍ត្រូវបានគេចាត់ទុកថា ជាការអូសបន្លាយដ៏វែងមួយសម្រាប់ក្រុមប្រទេសនេះ ដែលរួមមានសហរដ្ឋអាមេរិក ចិន និងរុស្ស៊ី។ ទោះយ៉ាងណា មេដឹកនាំទាំងនេះបានទទួលស្គាល់ផលប៉ះពាល់អវិជ្ជមាននៃសង្គ្រាមអ៊ុយក្រែនលើសេដ្ឋកិច្ចពិភពលោក ពោលគឺអតិផរណា កំណើនសេដ្ឋកិច្ចយឺត អសន្តិសុខស្បៀង និងថាមពល ការរំខានដល់ខ្សែច្រវ៉ាក់ផ្គត់ផ្គង់ និងហានិភ័យហិរញ្ញវត្ថុ ជាដើម។ ជាងនេះទៅទៀត ក្រុមប្រទេសទាំងនេះ បានថ្កោលទោសការឈ្លានពានរបស់រុស្ស៊ី និងបានអំពាវនាវឱ្យបញ្ចប់សង្គ្រាម តាមរយៈការគោរព

ស្មារតីនៃដំណោះស្រាយមុនៗរបស់អង្គការសហប្រជាជាតិ។ ចុចទីនេះដើម្បីអានបន្ត

## Brexit: នាយករដ្ឋមន្ត្រីអង់គ្លេស លោក Rishi Sunak ច្រានចោលកិច្ចព្រមព្រៀង ដែលពឹងផ្អែកលើច្បាប់របស់ EU

ប្រភព៖ BBC

លោក Rishi Sunak នាយករដ្ឋមន្ត្រីថ្មីរបស់ចក្រភពអង់គ្លេស បាននិយាយថា ក្រោយការសម្រេចនៃ Brexit ចក្រភពអង់គ្លេសនឹងមិនបន្តទំនាក់ទំនងណាមួយ ជាមួយសហភាពអឺរ៉ុប "ដែលពឹងផ្អែកលើការអនុលោមតាមច្បាប់របស់សហភាពអឺរ៉ុប" ទេ។ ការប្រកាសនេះ ធ្វើឡើងក្រោយមានរបាយការណ៍ថា មន្ត្រីមួយចំនួនក្នុងរដ្ឋាភិបាល ចង់ឃើញអង់គ្លេសឈានឆ្ពោះទៅរកកិច្ចព្រមព្រៀងបែបស្វីស ដែលចំណាកស្រុកជាមួយសហភាពអឺរ៉ុបនៅតែមាន តែមិនប៉ះពាល់ច្រើនដល់ការធ្វើពាណិជ្ជកម្ម។ ប្រទេសស្វីសអាចធ្វើពាណិជ្ជកម្មបានយ៉ាងងាយស្រួល ជាមួយសហភាពអឺរ៉ុប ប៉ុន្តែត្រូវតែអនុវត្តតាមច្បាប់មួយចំនួនរបស់ប្លុកនេះ។ កាសែត The Sunday Times បានរាយការណ៍ថា ឥស្សរជនជាន់ខ្ពស់របស់រដ្ឋាភិបាលអង់គ្លេស បាននិងកំពុងពិចារណាបន្តកិច្ចព្រមព្រៀងបែបស្វីសនេះ។ ប្រទេសស្វីសមិនមែនជាសមាជិកសហភាពអឺរ៉ុបទេ ប៉ុន្តែមានកិច្ចព្រមព្រៀងជាច្រើនជាមួយប្លុកពាណិជ្ជកម្មនេះ ហើយវិស័យឧស្សាហកម្មភាគច្រើនរបស់ខ្លួនអាចមានសិទ្ធិចូលរួម ក្នុងទីផ្សាររួមរបស់សហភាពអឺរ៉ុប។ ចុចទីនេះដើម្បីអានបន្ត

## សហភាពអឺរ៉ុប និយាយថាខ្លួនមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីច្បាប់កាត់បន្ថយអតិផរណារបស់លោក បៃដិន

ប្រភព៖ CNBC

សហភាពអឺរ៉ុប មានក្ដីបារម្ភយ៉ាងខ្លាំង អំពីច្បាប់កាត់បន្ថយអតិផរណារបស់សហរដ្ឋអាម៉េរិក ដោយនិយាយថាច្បាប់នេះ បំពានវិធានពាណិជ្ជកម្មអន្តរជាតិ។ សេចក្តីព្រាងច្បាប់ស្តីពីការកាត់បន្ថយពន្ធ សុខភាព និងអាកាសធាតុ ត្រូវបានអនុម័តដោយសមាជិកសភាអាម៉េរិក ក្នុងខែសីហា ឆ្នាំ២០២២ និងរួមបញ្ចូលការចំណាយជាង ៣៦៩ ប៊ីលានដុល្លារអាម៉េរិកលើគោលនយោបាយអាកាសធាតុ និងថាមពល។ សេចក្តីព្រាងច្បាប់នេះ ក៏រួមបញ្ចូលឥណទានពន្ធសម្រាប់រថយន្តអគ្គិសនី ដែលផលិតនៅអាម៉េរិកខាងជើង និងគាំទ្រខ្សែច្រវាក់ផ្គត់ផ្គង់ថ្មអគ្គិសនីរបស់សហរដ្ឋអាម៉េរិក។ ជារួម សហភាពអឺរ៉ុបមានការព្រួយបារម្ភអំពីរបាំងពាណិជ្ជកម្មថ្មី ដែលមានសក្តានុពលលើក្រុមហ៊ុនផលិតរថយន្តអគ្គិសនីនៅអឺរ៉ុប។ កូរ៉េខាងត្បូងក៏បានលើកឡើងនូវការព្រួយបារម្ភដូចគ្នានេះដែរ។ ចុចទីនេះដើម្បីអានបន្ថែម

## សហរដ្ឋអាម៉េរិកនិយាយថា ក្រុមប្រទេស G7 គួរបង្ហាញកម្រិតតម្លៃប្រេងរុស្ស៊ីក្នុងពេលឆាប់ៗ និងគួរកែសម្រួលជាប្រចាំ

ប្រភព៖ Reuters

មន្ត្រីជាន់ខ្ពស់ក្រសួងរតនាគារអាម៉េរិកបាននិយាយថា ក្រុមប្រទេស G7 គួរតែប្រកាសអំពីតម្លៃលើការនាំចេញប្រេងរុស្ស៊ីក្នុងពេលឆាប់ៗនេះ ហើយប្រទេសទាំងនេះគួរតែកែសម្រួលកម្រិតតម្លៃប្រេងនេះពីរទៅបីដងក្នុងមួយឆ្នាំ ជាជាងប្រចាំខែ។ គោលបំណង នៃយន្តការកំណត់តម្លៃ ដែលមិនធ្លាប់មានពីមុនមកនេះ គឺដើម្បីកាត់បន្ថយប្រាក់ចំណូលដែលរុស្ស៊ីទទួលបានពីប្រេងក្នុងការផ្គត់ផ្គង់ប្រតិបត្តិការសង្គ្រាមរបស់ខ្លួន និងដើម្បីរក្សាលំហូរប្រេងទៅកាន់ទីផ្សារពិភពលោកដើម្បីការពារការឡើងថ្លៃ។ ការកំណត់តម្លៃលើការនាំចេញផលិតផលប្រេងរុស្ស៊ី គ្រោងនឹងចាប់ផ្តើមនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ ខាងមុខ។ ចុចទីនេះដើម្បីអានបន្ថែម

## Trade Divide Could Cost Global Economy USD1.4 Trillion: IMF Chief Georgieva

Source: Business Standard

The rise of trade barriers against China and other countries over the past year could cost the global economy USD1.4 trillion, on top of the severe damage being done by the war in Ukraine, the head of the International Monetary Fund said. “What I am hoping to see is some reversals in policy blocks towards China and globally,” Kristalina Georgieva told Bloomberg Television. “The world is going to lose 1.5% of GDP just because of division that may split us into two trading blocs. This is USD1.4 trillion.” For Asia, the potential loss could be twice as bad, or more than 3% of GDP, because the region is more integrated into the global value chain, Georgieva said on the sidelines of the APEC’s economic leaders’ gatherings. Click here to read more

## WTO Report Shows G20 Trade Restrictions Increasing Amidst Economic Challenges

Source: WTO

In a context of economic uncertainty exacerbated by the COVID-19 pandemic, the war in Ukraine and the food security crisis, G20 economies between mid-May and mid-October 2022 introduced export restrictions at an increased pace, particularly on food and fertilizer, according to the 28th WTO Trade Monitoring Report on G20 trade measures issued in November. WTO Director-General Ngozi Okonjo-Iweala called on G20 countries, and all WTO members, to refrain from adopting new trade-restrictive measures that can further contribute to a worsening of the global economic outlook. “While some trade-restrictive measures have been lifted by G20 countries, the report indicates that the trend has been going in the wrong direction. Export restrictions contribute to shortages, price volatility, and uncertainty. Click here to read more

## APEC Finds Consensus on Pacific Free Trade, Ukraine War Fallout

Source: Nikkei Asia

The APEC summit ended on Saturday with leaders from the 21 member economies issuing a consensus statement that addresses the war in Ukraine, an issue that had left the group sharply divided all year. The mere act of issuing a statement had been considered a long shot for the grouping, which includes the U.S., China and Russia. Leaders recognized the Ukraine war's adverse effects on the global economy, namely inflation and slowed growth, food and energy insecurity, supply chain disruptions and financial risks. More indirectly, the group denounced Russia's aggression and called for an end to the war by referring to previous United Nations resolutions. Click here to read more

## Brexit: Rishi Sunak Rules Out Deal That Relies on EU Law Alignment

Source: BBC

The UK will not pursue any post-Brexit relationship with the EU "that relies on alignment with EU laws", Prime Minister Rishi Sunak has said. It follows reports that some in government want to move towards a Swiss-style deal, with less trading friction and more migration. Switzerland can trade easily with the bloc, but must follow some EU rules. He also said the UK was free to pursue trade deals with "the world's fastest-growing economies". The Sunday Times reported that senior government figures were considering pursuing a Swiss-style deal. Switzerland is not a member of the EU, but does have a several agreements with the trading bloc, and has access to the single market for most of its industries. Click here to read more

**EU Says It Has Serious Concerns about Biden's Inflation Reduction Act**

Source: CNBC

The European Union has "serious concerns" about the U.S. Inflation Reduction Act, saying it breaches international trade rules. The sweeping tax, health and climate bill was approved by U.S. lawmakers in August and includes a record USD369 billion in spending on climate and energy policies. The landmark package comprises tax credits for electric cars made in North America and supports U.S. battery supply chains. In essence, the EU is worried about potential new trade barriers on European electric vehicle producers. And they are not the only ones; South Korea, for instance, has also brought up the same concern. Click here to read more

**U.S Says G7 Should Soon Unveil Price Cap Level on Russian Oil, Adjust Regularly**

Source: Reuters

The G7 nations should soon announce the price cap on Russian oil exports and the coalition will probably adjust the level a few times a year rather than monthly, a senior U.S. Treasury official said. The aim of the unprecedented price cap mechanism is to reduce Russia's petroleum revenues funding its war machine while maintaining flows of its oil to global markets to prevent price spikes. A cap on exports of Russian oil products is slated to begin on 05 February 2023. Click here to read more

# សង្ខេបគោលនយោបាយ
# ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ និងសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន លើថ្លៃជីកសិកម្ម

១. ឯកឧត្តម តាត ពុធសាដារី ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម
២. លោកជំទាវ ចម និម្មល រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

សារគន្លឹះ៖

- ជំងឺរាតត្បាតកូវីដ-១៩ បានជះឥទ្ធិពលលើវិស័យជាច្រើនដោយផ្ទាល់ និងដោយប្រយោល ចាប់តាំងពីឆ្នាំ២០២០ មក។ ផលប៉ះពាល់នៃជម្លោះរវាងរុស្ស៊ី-អ៊ុយក្រែន លើភាពអាចរកបាន និងតម្លៃសមរម្យនៃផលិតផលជី បានក្លាយជាបន្ទុកមួយទៀត។
- វិបត្តិខាងលើនេះមិនត្រឹមតែប៉ះពាល់ផលិតផលជី និងថាមពលប៉ុណ្ណោះទេ តែក៏ប៉ះពាល់ដល់ថ្លៃស្បៀងអាហារ ព្រមទាំងឥទ្ធិពលអវិជ្ជមានផ្សេងទៀតលើផលិតកម្មកសិកម្ម និងសន្តិសុខស្បៀង។ មនុស្សរាប់ពាន់លានដុល្លារជួបភាពងាយរងគ្រោះដោយសារការឡើងថ្លៃអាហារ ថាមពល និងជី។ មនុស្សរាប់លាននាក់បានប្រឈមមុខនឹងបញ្ហាអសន្តិសុខស្បៀងអាហារដ៏ធ្ងន់ធ្ងរ ហើយផ្នែកខ្លះនៃទ្វីបអាហ្វ្រិកបាននិងកំពុងស្ថិតនៅលើបន្ទាត់នៃភាពអត់ឃ្លានរួចទៅហើយ។
- កសិករខ្នាតតូចកំពុងជួបការលំបាកក្នុងការទប់ទល់នឹងការចំណាយខ្ពស់នៃធាតុចូល ស្របនឹងអត្រាទិន្នផលដំណាំទាប។
- ពាណិជ្ជកម្ម ភស្តុភារកម្ម ផលិតកម្ម និងខ្សែចង្វាក់ផ្គត់ផ្គង់-តម្រូវការ ត្រូវបានរំខានក្នុងអំឡុងពេលជំងឺរាតត្បាត កូវីដ-១៩ និងជម្លោះដែលកំពុងបន្ត។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើ តម្រូវឱ្យមានការឆ្លើយតបជាគោលនយោបាយដូចជា៖

**ការឆ្លើយតបរយៈពេលខ្លី និងមធ្យម៖**

- ធ្វើការវាយតម្លៃយ៉ាងឆាប់រហ័សអំពីជំងឺរាតត្បាតកូវីដ-១៩ និងជម្លោះលើថ្លៃជីនៅតំបន់ជនបទ៖
  - ដើម្បីស្វែងយល់ពីក្រុម/កសិករដែលងាយរងគ្រោះបំផុត ដែលកំពុងប្រឈមនឹងការខ្វះខាតជី។ ដូច្នេះ គម្រោងឧបត្ថម្ភធនជីបណ្ដោះអាសន្នអាចត្រូវបានផ្ដល់អាទិភាពសម្រាប់រដូវខាងមុខ។
  - ដើម្បីប្រមូលទិន្នន័យស្ដីពីគោលនយោបាយពាណិជ្ជកម្មថាមពល និងជី ពីគេហទំព័ររបស់ប្រទេសនាំចេញសំខាន់ៗ ដើម្បីស្វែងយល់ពីសេណារីយ៉ូតម្លៃដែលអាចជួយកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន និងបង្កើតបរិយាកាសអំណោយផលសម្រាប់ជីដែលនាំចូល។
  - ដើម្បីជួយកសិករបង្កើនការប្រើប្រាស់ជីប្រកបដោយប្រសិទ្ធភាព៖ បរិមាណជីដែលបានប្រើប្រាស់ដោយដំណាំនៅពេលផលិត និងប្រមូលផល គឺជាអាទិភាពសំខាន់ ហើយកសិករគួរតែត្រូវបានលើកទឹកចិត្តឱ្យធ្វើពិពិធកម្មប្រភពជីក្នុងមូលដ្ឋាន (ផលិតក្នុងស្រុក)។
  - ការរកឃើញពីការវាយតម្លៃ អាចត្រូវបានគេប្រើប្រាស់ដើម្បីស្នើជាគម្រោងនៃការរួមបញ្ចូលគ្នារវាងជី សរីរាង្គ និងសារធាតុរ៉ែ ដែលជាការគ្រប់គ្រងភាពមានជីជាតិនៃដីដាំដុះដែលបត់បែនតាមអាកាសធាតុ។

**ការឆ្លើយតបរយៈពេលវែង៖**

- ការសម្របសម្រួលក្នុងតំបន់ និងការឆ្លើយតបគោលនយោបាយប្រកបដោយសុខដុមរមនា ក្នុងលក្ខខណ្ឌនៃគម្រោងអនុគ្រោះ គឺចាំបាច់ដើម្បីធានាថាជីអាចឆ្លងកាត់ព្រំដែនដោយរលូន។
- រក្សាវិបុលកម្មពាណិជ្ជកម្ម ដើម្បីធានាបាននូវលទ្ធភាពបន្ត និងលទ្ធភាពនៃជីពីប្រទេសផ្សេងៗ ដូច្នេះធានាបាននូវប្រភពជំនួសនៃជីពីប្រទេសនាំចេញសំខាន់ៗ ជាពិសេសប្រទេសចិន។
- ប្រើប្រាស់មធ្យោបាយចរចាការទូត ដើម្បីដកចេញការរឹតបន្តឹងការនាំចូល និងនាំចេញ គឺជាអាទិភាពទីមួយ ដើម្បីធានាថាជី និងថាមពលអាចបន្តដួញដូរក្នុងបណ្តាញដឹកជញ្ជូន។

## ១. ទស្សនៈផល

ជំងឺរាតត្បាតកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចពិភពលោករួចហើយ ហើយបានប៉ះពាល់ដល់វិស័យជាច្រើនដោយផ្ទាល់ និងដោយប្រយោលចាប់តាំងពីឆ្នាំ២០២០។ ពពកដ៏ខ្មៅងងឹតនៃសង្គ្រាមដែលកំពុងបន្ត គឺគ្មានទីបញ្ចប់នោះទេ។ ស្ថានភាពនេះបានរំកិលចូលទៅក្នុងឥទ្ធិពលដូមីណូ ដែលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យថាមពល ជី និងវិបត្តិអាហារនៅផ្នែកភាគច្រើននៃពិភពលោក។ ខ្សែចង្វាក់ពាណិជ្ជកម្ម ភស្តុភារកម្ម ផលិតកម្ម និងការផ្គត់ផ្គង់ និងតម្រូវការត្រូវបានរំខាន។ សង្គ្រាមអាចកាត់បន្ថយ កំណើនសកលលោក ប្រមាណ ១%។ ការកើនឡើងអតិផរណា បំណុល និងវិសមភាពប្រាក់ចំណូល ធ្វើឱ្យពិភពលោកកាន់តែលំបាកក្នុងការងើបឡើងវិញមិនត្រឹមតែពីជំងឺរាតត្បាត តែពីសង្គ្រាមទៀតផង។ បច្ចុប្បន្ននេះ កំណើនផលិតផលក្នុងស្រុកសរុបរបស់ពិភពលោកបានធ្លាក់ចុះពី ៥,៥% ក្នុងឆ្នាំ២០២១មកនៅត្រឹម ៤,១%% ក្នុងឆ្នាំ២០២២ និង ៣,២% ក្នុងឆ្នាំ២០២៣ ខណៈដែលអតិផរណារបស់ពិភពលោកកំពុងកើនឡើងយ៉ាងខ្លាំងនៅរង្វង់ ៩,១% ក្នុងខែមិថុនា ឆ្នាំ២០២២។

នៅពេលដែលវិបត្តិអ៊ុយក្រែនបានកើតឡើងស្របពេលនឹងវិបត្តិកូវីដ-១៩ ប្រជាជនប្រហែល ២៨៣ លាននាក់បានប្រឈមមុខនឹងបញ្ហាអសន្តិសុខស្បៀងយ៉ាងធ្ងន់ធ្ង រនៅក្នុងប្រទេសចំនួន៨១ ហើយប្រជាជនប្រហែល ៤៥ លាននាក់កំពុងស្ថិតនៅបន្ទាត់នៃភាពអត់ឃ្លានរួចហើយ។ យោងតាមសុន្ទរកថារបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិស្តីពីអ៊ុយក្រែននៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២២ សង្គ្រាមនៅអ៊ុយក្រែនបាននាំឱ្យមានការកើនឡើងយ៉ាងខ្លាំងនៃថ្លៃអាហារ ថាមពល និងជី ដោយសារតែរុស្ស៊ី និងអ៊ុយក្រែនជាអ្នកនាំចូលដ៏សំខាន់។ សង្គ្រាមនេះបានរំខានដល់ខ្សែចង្វាក់ផ្គត់ផ្គង់-តម្រូវការ និងបង្កើនថ្លៃនៃការដឹកជញ្ជូន ដែលដាក់សម្ពាធកាន់តែខ្លាំងលើប្រទេសកំពុងអភិវឌ្ឍន៍។ បន្ថែមពីលើនេះ មនុស្សប្រមាណ ១,២ ពាន់លាននាក់ បានក្លាយជាជនងាយរងគ្រោះខ្លាំង ពីការឡើងថ្លៃអាហារ ថាមពល និងជី នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ៧៤។

កាតព្វកិច្ចបំណុលកើនឡើងប្រហែល ១៦% នៃប្រាក់ចំណូលពីការនាំចេញរបស់ប្រទេសកំពុងអភិវឌ្ឍន៍។ នៅក្នុងរដ្ឋកំពុងអភិវឌ្ឍដែលជាកោះតូចៗ តួលេខនៃបំណុលមានប្រមាណ ៣៤% ដោយសារតែការកើនឡើងអត្រាការប្រាក់ និងតម្រូវការក្នុងការបង់ប្រាក់សម្រាប់ការនាំចូលដែលមានឡើងថ្លៃ។ នៅតែខែមីនា ឆ្នាំ២០២២ តម្លៃស្រូវសាលីបានកើនឡើងប្រមាណ ២២%, ពោតប្រមាណ២១% និងស្រូវបាឡេ ប្រមាណ៣១% ។ តម្លៃប្រេងចេញពីផលិតកម្ម Brent នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២

បានកើនឡើងខ្ពស់ជាង៦០% ដែលកំណើននេះខ្ពស់ជាងពេលដូចគ្នាកាលពីឆ្នាំមុន។ តម្លៃឧស្ម័នធម្មជាតិ និងជីក៏បានកើនឡើងជាងទ្វេដង ក្នុងរយៈពេលដូចគ្នា។

**តារាងទី១៖ កំណើនសេដ្ឋកិច្ចកម្ពុជា និងអត្រាអតិផរណា**




ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ី ២០២២

**តារាងទី២៖ ការចូលរួមចំណែកតាមវិស័យ ដល់កំណើនផលិតផលក្នុងស្រុកសរុប**




ប្រភព៖ ក្រសួងកសិកម្ម រុក្ខប្រម៉ាញ់ និងនេសាទ ២០២២

កំណើនសេដ្ឋកិច្ចកម្ពុជាបានកើនឡើងក្នុងរង្វង់ ៧,៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាងពីរទសវត្សរ៍ ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០១៩។ ទោះជាយ៉ាងណាក៏ដោយ ជំងឺរាតត្បាតកូវីដ-១៩ បង្ករជាផលប៉ះពាល់អវិជ្ជមានលើកំណើនផលិតផលក្នុងស្រុកសរុប ដែលបានធ្លាក់ចុះនៅ -៣,១% ក្នុងឆ្នាំ២០២០។ កំណើននេះបានស្ទុះងើបឡើងវិញពី ៣,០% ក្នុងឆ្នាំ២០២១ ដល់៥,៣% ក្នុងឆ្នាំ២០២២ ហើយត្រូវបានគេរំពឹងថានឹងកើនឡើងដល់ប្រមាណ៦,៥% ក្នុងឆ្នាំ២០២៣។ អតិផរណាអាចធ្លាក់ចុះពី៤,៧%

ក្នុងឆ្នាំ២០២២ មកត្រឹម២,២% ក្នុងឆ្នាំ២០២៣។ កំណើនវិជ្ជមាននេះ បានមកពីការរួមចំណែកពីការយកពន្ធលើផលិតផល ការឧបត្ថម្ភធនតិច សេវាកម្ម ឧស្សាហកម្ម និងកសិកម្ម ជាដើម។

ដោយសារការរួមចំណែកតាមវិស័យដល់កំណើនសេដ្ឋកិច្ចកម្ពុជា វិស័យសេវាកម្មបានធ្លាក់ចុះបន្តិចពី៤២,៣% ក្នុងឆ្នាំ២០១៧ មកប្រមាណ ៣៧% ក្នុងឆ្នាំ២០២១ ខណៈដែលឧស្សាហកម្មបានកើនឡើងបន្តិចម្តងៗពីរង្វង់៣២,៨% ក្នុងឆ្នាំ២០១៧ ដល់រង្វង់៣៨.៥% ក្នុងឆ្នាំ២០២១។ វិស័យកសិកម្មនៅមានស្ថិរភាពកំណើនក្នុងរង្វង់ ២៤,៩% នៅឆ្នាំ២០១៧ និង ២៤,៤%% នៅឆ្នាំ២០២១ ប៉ុន្តែនិន្នាការនេះបានថយចុះបន្តិចក្នុងឆ្នាំ២០១៩ (តារាងទី១ & ២)។

## ២. និន្នាការសកលនៃទីផ្សារទំនិញកសិកម្ម

តារាងទី ៣ បានបង្ហាញថា ប្រទេសរុស្សី និងអ៊ុយក្រែនគឺជាអ្នកផលិតដ៏សំខាន់នៃពោត គ្រាប់ពូជ colza ស្រូវបាឡេ ស្រូវសាលី និងប្រេងផ្កាឈូករ័ត្ន និងគ្រាប់ពូជផ្កាឈូករ័ត្ន។ បើគិតពីចំណែកក្នុងទីផ្សារទំនិញកសិកម្ម ប្រទេសអ៊ុយក្រែនមានប្រេងផ្កាឈូករ័ត្ន និងគ្រាប់ពូជផ្កាឈូករ័ត្ន ជាង ៣៦% ដែលខ្ពស់ជាងប្រទេសរុស្សីដែលមានតែ ១៧%។ សម្រាប់ការផលិតពោត ប្រទេសអ៊ុយក្រែមានដល់១៣% នៃទីផ្សារពោតពិភពលោក ខណៈប្រទេសរុស្សីមានត្រឹមតែ ១% ប៉ុណ្ណោះ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍គឺថា ប្រទេសទាំងពីរមានចំណែកក្នុងទីផ្សារសកល ប្រហាក់ប្រហែលសម្រាប់ផលិតផលស្រូវបាឡេ ដែលប្រទេសរុស្សីមាន ១២% ហើយប្រទេសអ៊ុយក្រែនមាន១១%។

**តារាងទី៣៖ ទំនិញកសិកម្មសម្រាប់ទីផ្សារសកល រវាងប្រទេសរុស្សី និងប្រទេសអ៊ុយក្រែន**




**ប្រភព៖ UNCTAD 2022**

តារាងទី៤ បានបង្ហាញថា ប្រទេសរុស្សី និងប្រទេសអ៊ុយក្រែននៅតែជាអ្នកនាំចេញដ៏សំខាន់នៃពោត និងស្រូវសាលី។ សម្រាប់ផលិតផលស្រូវសាលី រុស្សីមានចំណែក ១៦% នៃការនាំចេញសកល ខណៈអូស្ត្រាលីមានប្រមាណ ១៣% និងអាម៉េរិកមាន១១% រីឯសហភាពអឺរ៉ុបមានដល់ ១៨%។ សម្រាប់ផលិតផលពោត សហរដ្ឋអាម៉េរិកនៅតែជាអ្នកនាំចេញពោតច្រើនជាងគេដែលមានចំនួនប្រមាណ ៣៣% ខណៈដែលប្រទេសអាហ្សង់ទីនមានប្រមាណ ២២% ប្រទេសប្រេស៊ីលមានប្រមាណ ១៧% និងប្រទេសអ៊ុយក្រែនមានប្រមាណ១៤%។ ចំពោះការនាំចេញស្រូវអង្ករវិញ អូស្ត្រាលីមានចំណែកជាភាគរយខ្ពស់បំផុតរហូតដល់ទៅ ២៦% ខណៈសហភាពអឺរ៉ុបមាន ២២% ប្រទេសអ៊ុយក្រែនមាន ១៧% និងរុស្សីមាន ១៣%។

## តារាងទី៤៖ អ្នកនាំចេញសំខាន់ៗនៃស្រូវសាឡី ពោត និងស្រូវបាឡេ ក្នុងឆ្នាំ២០២១/២០២២




ប្រភព៖ USDA ២០២២

### ២.១. និន្នាការជីសកល

តារាងទី៥បង្ហាញថា ប្រទេសរុស្ស៊ីក្លាយជាប្រទេសនាំចេញជីអាសូតលំដាប់កំពូលរបស់ពិភពលោក (១៥%) ហើយក៏ជាអ្នកផ្គត់ផ្គង់សារធាតុប៉ូតាស្យូមនាំមុខគេទីពីរ (១៩%) និងជាអ្នកនាំចេញជីផូស្វ័រទីបី (១៤%) លើពិភពលោក។ ប្រទេសចិននៅតែជាចំណែកទីផ្សារទីមួយនៃផូស្វាត (២៥%) និងទីពីរនៃអាសូត (១៣%)។

## តារាងទី៥៖ ទីផ្សារសកលនៃជី ក្នុងឆ្នាំ២០១៩




ប្រភព៖ FAOSTAT by Hebebrand and Laborde ២០២២

ប្រទេសដែលប្រើប្រាស់ជីភាគច្រើន គឺរងផលប៉ះពាល់ដោយប្រភេទនៃដំណាំ តម្លៃនៃជី ភាពអាចរកបាន តម្លៃអាចទិញបាន និងអាត្រាប្រើប្រាស់បានតាមសណ្ឋានដី។ បើគិតជាហិកតា ប្រទេសចិនគឺជាប្រទេសដែលប្រើប្រាស់ជីច្រើនជាងគេ ដែលមានប្រហែល ៣៤០ គីឡូក្រាម/មួយហិកតា ខណៈដែលឥណ្ឌាគឺជាប្រទេសប្រើប្រាស់ច្រើនជាងគេទីពីរ ដោយសារតែរដ្ឋាភិបាលឥណ្ឌាបានឧបត្ថម្ភធនយ៉ាងច្រើនដល់កសិកររបស់ខ្លួន។ ដោយឡែក អាម៉េរិកគឺជាប្រទេសដែលប្រើប្រាស់ជីច្រើនជាងគេទីបីដែលមានប្រមាណ ១០% នៃប្រទេសប្រើប្រាស់ជីលើពិភពលោក សម្រាប់ផលិតកម្មគ្រាប់ធញ្ញជាតិ និងប្រេង។ ប្រទេសប្រេស៊ីលកាណាដា និងម៉ិកស៊ិក ពឹងផ្អែកលើជីដែលនាំចូលប្រមាណ ៦០% នៃជីរបស់ពួកគេ ខណៈដែលសហរដ្ឋអាម៉េរិកនាំចូលជិត ២០% នៃជីដែលខ្លួនប្រើប្រាស់។

ក្នុងករណីប្រទេសកម្ពុជា ប្រទេសនេះបាននាំចូលប្រមាណ ២,១ លានតោន (២,១៥៧,២៨៥,០៧ តោន) ក្នុងនោះមានសារធាតុគីមី ១១៨,៦៩៦,៤៥៤ តោន និងជី និងថ្នាំសម្លាប់ស្មៅចំនួន ២,០៣៨,៥៨៨,៦២ តោន។ នៅឆ្នាំ ២០២០ កម្ពុជាក្លាយជាប្រទេសនាំចូលជីធំជាងគេទី ៥៨ លើពិភពលោក (២៣៣ លានដុល្លារអាម៉េរិក) ដែលមានប្រភពចម្បងពីប្រទេសវៀតណាម (១២៩ លានដុល្លារអាម៉េរិក) ថៃ (៨២,៩ លានដុល្លារអាម៉េរិក) ចិន (៩,៥៦ លានដុល្លារអាម៉េរិក) ម៉ាឡេស៊ី (១,៦៥ លានដុល្លារអាម៉េរិក) និងអូម៉ង់ (១,៤៧ លានដុល្លារអាម៉េរិក)។ ទោះជាយ៉ាងណាក៏ដោយ មិនទាន់មានព័ត៌មានណាមួយដើម្បីបញ្ជាក់អំពីបរិមាណនៃការប្រើប្រាស់ជីដែលរងផលប៉ះពាល់ដោយប្រភេទនៃដំណាំ តម្លៃនៃជី ភាពអាចរកបាន តម្លៃអាចទិញបាន និងអាត្រាប្រើប្រាស់បានតាមសណ្ឋានដីនៅក្នុងប្រទេសកម្ពុជាឡើយ។

